# ការសំភាសន៍របស់អ្នកមីង លុក អិត

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ លុក អិត

## <u>ការសង្ខេបប្រវត្តិរបស់របស់មីង លុក អិត</u>

អ្នកមីង លុក អិត មានអាយុ 51ឆ្នាំ ហើយនៅក្នុងឆ្នាំ2018។អ្នកមីង លុក អិត មានភេទស្រីអ្នកមីង លុក អិត មានទីលំនៅបច្ចុប្បន្ននៅភូមិដក់ពរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍នេះ ត្រូវបានរៀបចំឡើងដោយសកលវិទ្យល័យមួយដែរនៅអាមេរិចដែរមានឈ្មោះBYUចឹង ហើយដាយសារ តែសកលវិទ្យាល័យមានគោបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូបនចៅជំនាន់ក្រោយៗ អោយពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយនឹងប្រវត្តិរបស់ដូនតាចឹងហាសមីង ហើយនៅពេលដែរខ្ញុំសំភាសន៍ ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា [www.cambodianoralhistories.byu.edu](http://www.cambodianoralhistories.byu.edu) ចឹងហាស ចឹងតើមីង យល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខៈ ដាក់ថាម៉េចចឹង

កៈ ចង់និយាយមីងយល់ព្រមអោយខ្ញុំដាក់ប្រវត្តិរបស់មីងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុក អោយមីងមួយទៀតទេមីង?

ខៈ អត់អស់លុយណាហីមីង?

កៈ បាទអត់អស់លុយទេ

ខ៖ បើអត់អស់លុយដាក់ទៅ តែបើអត់អស់លុយអត់ដាក់ទេនឹង

ក៖ អូ៎!ពួកយើងមិនគិតលុយទេមីង មួយនឹងពួកយើងធ្វើដោយស្ម័គ្រចិត្តចឹងណាស់ អត់មានគិតលុយទេ?

ខ៖ ដាក់ទៅចឹង

ក៖ ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍មីង ខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍មីងគឺធ្វើនៅ ថ្ងៃទី13 ខែ2 ឆ្នាំ2018 ខ្ញុំសំភាសន៍នៅភូមិដក់ពរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺត្រូវទេមីង?

ខ៖ ចា៎!ត្រូវហើយនឹង

ក៖ ចឹងសំរាប់មីងមានឈ្មោះពេញនឹងឈ្មោះអីគេដែរមីង?

ខ៖ ខ្ញុំដាក់ឈ្មោះអេង

ក៖ ឈ្មោះពេញតែម្តងនឹងហាស ឈ្មោះអោយដូចអត្តសញ្ញាណប័ណនឹងមីង?

ខ៖ ឈ្មោះដូចអត្តសញ្ញាណប័ណនឹងឈ្មោះលុក អិត

ក៖ ចុះមានឈ្មោះលុក អិត ចុះមានឈ្មោះហៅក្រៅដែរទេមីង?

ខ៖ គ្មានឈ្មោះណាទៀតផងនឹង

ក៖ ចុះមីងដាក់ឈ្មោះអេង មិញនឹងឈ្មោះអីគេមីង?

ខ៖ ខ្ញុំចេះតែដាក់ទៅនឹង ធ្វើម៉េចឥឡូវនឹងដាក់ឈ្មោះពិតក៏ដាក់ទៅ

ក៖ ចឹងការនៅក្មេងមានហៅឈ្មោះអីផ្សេងដែរទេ?

ខ៖ អត់មានទេ

ក៖ ចុះមីងមានអាយុប៉ុន្មានដែរមីងសព្វថ្ងៃនឹង?

ខ៖ ខ្ញុំមានអាយុ51ឆ្នាំហើយនឹង

ក៖ អូ៎!មីងអាយុ51ឆ្នាំមីងអាយុច្រើនដែរ ចុះមីងកើតនៅថ្ងៃខែឆ្នាំណាមីងមានចងចាំទេ?

ខ៖ ខ្ញុំកើតនៅឆ្នាំ1967

កៈ  មីងកើតនៅឆ្នាំ1967 ចុះខែមីងមានចងចាំខែអីទេ?

ខៈ  នឹងខែ8

កៈ  ខែ8 ចុះទីប៉ុន្មានដែរមីងមានចងចាំទេ?

ខៈ  ទីនឹងគឺទី9

កៈ  ចុះឆ្នាំច័ន្ទគតិមីងកើតឆ្នាំអីគេដែរមីង?

ខៈ  ឆ្នាំខ្មែរមែន?

កៈ  លក្ខណៈថាឆ្នាំជូត ឆ្លូវ ខាល ថោះហាសមីង?

ខៈ  ខ្ញុំឆ្នាំវក

កៈ ចុះមីងកើតនៅភូមិឃុំ ស្រុកអីគេដែរមីង?

ខៈ  ខ្ញុំកើតនៅអ្នកលេង ប៉ុន្តែដាក់ភូមិនឹងហើយកុំអោយវែងឆ្ងាយទេ

កៈ  នៅភូមិនឹងហោសមីង?

ខៈ  នៅភូមិដក់ពរ

កៈ  ភូមិដក់ពរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កុំវាល់តែភ្លេច?

ខៈ  ចា៎នឹងហើយ

កៈ  ចុះមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខៈ  ខ្ញុំមានបងប្អូនចំនួន6នាក់

កៈ  ចុះមីងជាកូនទីប៉ុន្មានដែរមីង?

ខៈ  ខ្ញុំជាកូនទៅ5

កៈ  ចុះមានស្រីប៉ុន្មាននឹង ប្រុសប៉ុន្មានដែរមីង?

ខៈ  មានស្រី4នាក់ នឹងប្រុស2នាក់

កៈ
ចុះមីងអាចរៀបរាប់ឈ្មោះបងប្អូនរបស់មីងបានទេដូចថាគាត់មានឈ្មោះអីគេខ្លះដែរចឹង
ណាស់មីង?

ខៈ ឈ្មោះបងប្រុសនឹងឈ្មោះនាគ ម៉េង

កៈ ចុះបងទី2នឹងមានឈ្មោះអីគេដែរមីង?

ខៈ បងទី2នឹងឈ្មោះគីម ហួយ

កៈ ចុះបងទី3វិញមីង?

ខៈ ទៅ3នឹងឈ្មោះលាក ហួត

កៈ ទី4នឹងឈ្មោះអីគេដែរមីង?

ខៈ ទី4ឈ្មោះគំ គួយ

កៈ ទី5នឹងមីងចុះទៅទី6វិញមីង?

ខៈ ទី6នឹងឈ្មោះលុក ហីម

កៈ ចឹងសំរាប់មីងមានចងចាំសាច់រឿងអីជាមួយពួកគាត់ដែរទេ
លក្ខណះថាកាលពីក្មេងៗមីងមានធ្លាប់ លេងអីគេដូចជាឡឹកបាយឡ លេងចុយ
លេងអីចឹងមីង?

ខៈ ខ្ញុំធំនឹងធំពេលដែរអាពតហើយនឹង

កៈ ចឹងមានន័យថាពេលដែរមីងធំនឹងពេលដែរអាពតហើយណាមីង?

ខៈ ចា៎!នឹងហើយ

កៈ ចឹងមីងធ្លាប់បានធ្វើអីគេខ្លះដែរទៅចឹង
ហើយមីងធ្លាប់បានលេងអីជាមួយបងប្អូនរបស់មីងដែរទៅចឹង?

ខៈ កាលពីក្មេងនៅជំនាន់ណុងកាលពីនៅក្មេងនឹងខ្ញុំមិនសូវចាំទេ
ពេលដែរធំហើយនឹងទៅកងអស់ ហើយនឹង

ក៖ អូ!ចឹងមានន័យថាពេលណុងមីងធំឡើងនឹងមីងទៅអាពតតែម្តងហោសមីង?

ខ៖ ចា៎!នឹងហើយកាលពីអាយុ5-6ឆ្នាំនឹងគេអោយទៅរើសអាចម៍គោ គេអោយទៅកាប់កន្ទ្រាំងខែតអី ហើយនឹង

ក៖ ប៉ុន្តែនៅណាដែរមីង?

ខ៖ ដាក់ភូមិនឹងតែម្តងនឹង

ក៖ ប៉ុន្តែមីងអោយប្រាកដថានៅភូមិណាដែរទេ កាលពីមីងអាយុ5-6ឆ្នាំណាស់មីង

ខ៖ អូ!នៅច្រើនភូមិណាស់

ក៖ ប៉ុន្តែមីងអាចប្រាប់ថានៅភូមិណាខ្លះដែរទេ?

ខ៖ នឹងទៅភូមិព្រែកក្មេងចឹងទៅ

ក៖ ដល់ពេលទៅដល់ភូមិព្រៃក្មេងចឹងគេអោយមីងទៅលើកអាចម៍គោអីចឹងទៅ?

ខ៖ ដើររើសអាចម៍គោតាមស្រែអីចឹងទៅ

ក៖ បន្ទាប់មកគេអោយទៅ?

ខ៖ បន្ទាប់មកគេអោយទៅកាប់កន្ទ្រាំងខែតយកមកធ្វើជីអីនៅជំនាន់អាពតនឹងណាស់

ក៖ អូ!បាទមីងចុះពេលណុងមីងនៅជាមួយគ្រួសារអីដែរទេមីង?

ខ៖ អត់ទេអត់បាននៅជាមួយឪពុកម្តាយទេនៅបែកនឹង

ក៖ ប៉ុន្តែឪពុកម្តាយរបស់មីងទៅណាទៅពេលណុង?

ខ៖ ឪពុកម្តាយគេយកទៅដាក់នៅកង ដូចថាឪពុកចឹងគេយកទៅដាក់នៅកងដូចថាធ្វើត្រឹមយកទៅ ជ្រលូកក្រម៉ាអីចឹងទៅណាស់

ក៖ អូ!គាត់ធ្វើចឹងឪពុករបស់មីង?

ខ៖ ហើយម្តាយរបស់ខ្ញុំគេអោយទៅរែកទំនុប រែកដីធ្វើទំនុបនឹងរែកដីអីចឹងទៅណាស់

ក៖ អូ!គាត់ធ្វើចឹងហោសមីង?

ខ៖ នឹងហើយធ្វើចឹង

ក៖ ប៉ុន្តែមិនមែននៅកងធំៗគេហៅកងចល័តនឹងហោសមីង?

ខ៖ មិនមែនទេកងចល័តនឹងតែកងនារីទេ

ក៖ អូ៎!ប៉ុន្តែពេលណុងមីងនៅកងកុមារ?

ខ៖ ខ្ញុំនៅកងកុមារនឹង

ក៖ ចុះពេលណុងបងៗរបស់មីងគេអោយទៅណាទៅ?

ខ៖ បងៗរបស់ខ្ញុំនឹងដូចថាគេអាយុ17-18ឆ្នាំនឹងគេអោយធ្វើជាកងនារីឈានមុខ

ក៖ អូ៎!ធ្វើជាកងនារីឈានមុខណាមីង?

ខ៖ នឹងនារី55 នឹងនារីពិសេសដែរនឹង

ក៖ អូ៎!គេគិតចឹងណាមីង?

ខ៖ ចា៎!គេមានអ្នកធំ អ្នកទុចអីចឹងទៅណាស់

ក៖ បន្ទាប់ពីគេជំលាសមីងទៅភូមិអីគេមិញមីង?

ខ៖ ភូមិព្រៃក្មេង

ក៖ ពេលដែរគេអោយទៅភូមិព្រៃក្មេងនឹងមកគេជំលាសមីងទៅណាទៀតទៅ?

ខ៖ មានច្រើនភូមិណាស់
ចឹងទៅពេលដែរចេញពីភូមិព្រៃក្មេងចឹងទៅគេក៏ដក់ទៅនៅតាមបឹងស្រែនឹង
នឹងតាមភូមិទៅណា

ក៖ ប៉ុន្តែគេអោយមីងទៅធ្វើដដែល ទៅលើកអាចម៍គោ?

ខ៖ ហើយគេអោយលើកអាចម៍គោ
ដើរដួសតាមបង្គន់អីចឹងទៅគេរើសអ្នកធំអ្នកតូចអីចឹងទៅណាស់ ណាគេខ្ពស់ៗ

ក៖ គេដួសយកមកធ្វើជីនឹងហោសមីង?

ខ៖ នរណាគេអោយរែកទឹកកើតគេអោយរែកទឹកទៅ នរណាគេអោយទូលកើតគេអោយទូលកាលពី ជំនាន់ពលពតនឹង

ក៖ ចុះគេមានជំលាសទៅខេត្តណាទៀតអត់?

ខ៖ មានតើ!

ក៖ មានអោយខេត្តណាដែរទៅមីង?

ខ៖ ដូចថានៅណានៅម្តុំព្រៃក្មេងចឹងទៅ ចេញពីព្រៃក្មេងទៅស្វាយអំពាចឹងទៅ ចេញពីស្វាយអំពាចឹងទៅ ទៅភូមិទូលចឹងទៅ

ក៖ ប៉ុន្តែនៅក្នុងខេត្តកំពង់ស្ពឺនឹងទេ?

ខ៖ ចាំ!នៅខេត្តនឹងតើ!

ក៖ ប៉ុន្តែអត់មានទៅខេត្តនាផ្សេងៗទេ ដូចជាទៅកំពង់ចាម ទៅខេត្តស្វាយរៀងអី រឺខេត្តអីផ្សេងៗទេណ មីង?

ខ៖ អត់មានទេពីព្រោះខ្ញុំជាកុមារតូចៗគេមិនអោយទៅតាមខេត្តទេ គេអោយទៅតែនារីៗទេនឹង

ក៖ ប៉ុន្តែឪពុកម្តាយរបស់មីងនឹងមានទៅខេត្តផ្សេងអត់មីង រឺនៅតែខេត្តកំពង់ស្ពឺនឹងដែរមីង?

ខ៖ ឪពុកម្តាយរបស់ខ្ញុំនឹងមានទៅខេត្តផ្សេងគេអោយលើកបន្លែទៅដល់ណា ក៏ត្រូវតែទៅដល់នឹងទៅ

ក៖ ប៉ុន្តែពួកគាត់ទៅដល់ណាខ្លះទៅមីងមានដឹងអត់?

ខ៖ មិនដឹងថាទៅដល់ណាខ្លះខ្ញុំមិនសូវចាប់អារម្មណ៍ដែរនឹងកាលនឹង ប៉ុន្តែគ្រាន់តែថាបន្លែនឹងគេអោយ ទៅលើកទាំងយប់ នឹងលើកទាំងថ្ងៃនឹង

ក៖ គ្រាន់តែគេមានម៉ោងកំនត់គេហីមីង?

ខ៖ ជំនាន់អាពតគេមានម៉ោងគេ ដូចថាម៉ោង6ព្រឹកគេអោយយើងរែកហើយម៉ោង12ឈប់ហូបបាយនឹង

ហើយដល់ម៉ោង1រែករហូតដល់ម៉ោង5 ហើយម៉ោង5ឈប់
ហើយចាប់ផ្តើមរែករហូតដល់ម៉ោង12យប់បាន ឈប់

ក៖ ចុះរបបអាហារសំរាប់ក្មេង នឹងមនុស្សចាស់មានការខុសគ្នាយ៉ាងម៉េចដែរទៅមីង?

ខ៖ របបក្មេងពេលណុងគេអោយហូបបបរ

ក៖ ចុះចាស់វិញមីង?

ខ៖ ចាស់អត់មានទេ ចាស់នឹងគេអោយហូបតែថ្ងៃត្រង់នឹងល្ងាចទេនឹង

ក៖ ប៉ុន្តែក្មេងមានបបរពេលព្រឹកដែរ?

ខ៖ ដូចថាខ្ញុំនឹងអាយុ12ឆ្នាំចឹងទៅគេហៅកុមារឈានមុខ
ហើយអាយុ10ឆ្នាំគេហៅកុមារធម្មតានឹង

ក៖ អូ៎!គេគិតតាមអាយុណាមីង?

ខ៖ ចា៎!គេគិតចឹងហាសណាស់

ក៖ ចុះពេលនឹងនិយាយពីសុខភាពវិញ
ចុះបើយើងឈឺអីចឹងពេលណុងគេអោយយើងធ្វើអីទៅកុមារ ហាសមីង?

ខ៖ គេមានពេទ្យគេ

ក៖ គេមានពេទ្យគេដែរហោសមីង?

ខ៖ គេហៅពេទ្យគម្មកិច្ចគេនោះ

ក៖ គេព្យាបាលអោយយើងដែរហោសមីង?

ខ៖ ចា៎!គេមើលតើ

ក៖ ចុះបើយើងលក្ខណះថាជាឈឺក្បាល ឈឺពោះ វិលមុខ រាគអីចឹងធ្វើម៉េចទៅ?

ខ៖ ដល់ពេលចឹងយើងទៅប្រាប់វប្បធិម

ក៖ ចុះពេលដែរប្រាប់ចឹងទៅគេអោយថ្នាំមកអោយហើយណាមីង?

ខ៖ ដល់ពេលប្រាប់គេចឹងទៅគេអោយពេទ្យនៅកន្លែងគម្មកិច្ចអោយយើងចឹងទៅ

កៈ ចុះបងប្អូនរបស់មីងគាត់នៅណាដែរមីងសព្វថ្ងៃណាស់

ខៈ សព្វថ្ងៃនឹងខ្លះក៏នៅភ្នំពេញចឹងទៅ ខ្លះក៏នៅលាប់លែងចឹងទៅ

កៈ លាប់លែងនឹងនៅណាដែរមីង?

ខៈ លាប់លែងនឹងនៅខេត្តកំពង់ស្ពឺនឹង ប៉ុន្តែនៅស្រុកគងពិសី

កៈ អូ!នៅស្រុកគងពិសីយើងនឹងហោសមីង?

ខៈ ចាំ!នឹងហើយ

កៈ ចុះបងរបស់មីងគាត់នៅភ្នំពេញនឹងគាត់ធ្វើអីគេដែរមីង?

ខៈ គាត់ចាស់ៗអស់ហើយនឹង

កៈ អូ!គាត់នៅផ្ទះនៅជាមួយកូនចៅចឹងទៅ?

ខៈ នឹងហើយនៅជាមួយកូនចៅ ហើយកូនចៅចិញ្ចឹមចឹងទៅណាស់

កៈ ហើយសូម្បីតែបងរបស់មីងនៅគងពិសីនឹងក៏គាត់នៅជាមួយកូនចៅដែរណាមីង?

ខៈ ចាំ!នៅជាមួយកូនចៅដែរនឹង

កៈ ចុះឪពុករបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខៈ ឪពុករបស់ខ្ញុំគាត់ស្លាប់យូរហើយ គាត់ឈ្មោះកង់ សែធុន

កៈ ចុះគាត់អាយុប៉ុន្មានដែរមីងមានចងចាំទេ?

ខៈ បើនៅទាល់ឥឡូវនឹងហោស ?

កៈ បាទមីងនៅទាល់ឥឡូវនឹងមីង?

ខៈ នៅទាល់តែឥឡូវនឹងគាត់អាយុច្រើនណាស់មិនចាំទេគាត់អាយុប៉ែតជាងហើយនឹង

កៈ គាត់ប្រហែលជាប៉ែតប៉ុន្មានដែរមីង?

ខៈ ប្រហែលជាអាយុ85ឆ្នាំអីនឹងមើលទៅ

កៈ គាត់អាយុ85ឆ្នាំ ចុះគាត់កើតនៅឆ្នាំណាមីងមានចងចាំទេ?

ខ៖  ខ្ញុំអត់បានចងចាំទេនេះ
ចុះក្មួយឯងគិតមើលឥឡូវនឹងឆ្នាំ2018ហើយគាត់អាយុ85ឆ្នាំក្មួយឯងដកទៅ ដឹងហើយ

ក៖  គាត់កើតនៅឆ្នាំ1933 ចុះគាត់កើតនៅណាមីងមានដឹងទេ?

ខ៖  គាត់កើតនៅស្រុកចិន

ក៖  គាត់កើតនៅចិនហោស ចឹងមានន័យថាមីងកូនកាត់ចិន?

ខ៖  ចា៎!គាត់ចិនឆៅនឹង

ក៖  ចុះម្ដាយរបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខ៖  ម្ដាយរបស់ខ្ញុំគាត់ជនជាតិខ្មែរនឹង

ក៖  ប៉ុន្តែគាត់មានឈ្មោះអីគេដែរមីង?

ខ៖  គាត់ឈ្មោះលុក ង៉ែត

ក៖  ប៉ុន្តែគាត់អាយុប៉ុន្មានដែរមីង?

ខ៖  គាត់ពីគាត់ស្លាប់នឹងអាយុ61ឆ្នាំ

ក៖  ប៉ុន្តែយាយនឹងប្អូនតាប៉ុន្មានឆ្នាំដែរទៅមីង?

ខ៖  គាត់ប្អូនគ្នា7ឆ្នាំនឹង

ក៖  ចឹងមានន័យថាយាយកើតនៅឆ្នាំ1940?

ខ៖  នឹងហើយ

ក៖  ចុះយាយកើតនៅណាមីងមានដឹងទេ?

ខ៖  កើតនៅគងពិសីដែរនឹង

ក៖  កើតនៅស្រុកគងពិសីហោសមីងចុះតាគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខ៖  កាលពីនៅសង្គម រីមួយក៏នៅអាពត?

កៈ  កាលពីនៅសង្គម នឹងនៅអាពតនឹងគាត់ធ្វើអីគេខ្លះដែរទៅមីង
សំរាប់ចិញ្ចឹមជីវិតណាស់មីង?

ខៈ  កាលពីនៅសង្គមនឹងគាត់ចិនកាប់ជ្រូក

កៈ  ចុះពេលដែរជំនាន់អាពតនឹងគេអោយគាត់ធ្វើអីគេដែរមីង?

ខៈ  ដល់ពេលដែរជំនាន់អាពតនឹងគេដាក់គាត់ចូលក្នុងឃ្លាំងអាជ្រលូកក្រម៉ាខៀវនឹង

កៈ  ចុះឪពុករបស់មីងគាត់ស្លូត រឺមួយក៏កាចដែរមីង?

ខៈ  គាត់ស្លូតនឹង

កៈ  ចុះម្ដាយរបស់មីងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ  ម្ដាយរបស់ខ្ញុំនឹងគាត់លក់សាច់ជ្រូកជាមួយប៉ារបស់ខ្ញុំតាំងពីសង្គមមកនឹង

កៈ  ចុះកាលពីជំនាន់ពលពតគេអោយគាត់ធ្វើអីគេដែរទៅមីង?

ខៈ  កាលពីជំនាន់ពលពតនឹងគេអោយគាត់ធ្វើបន្លែនឹង

កៈ  ចុះម្ដាយរបស់មីងគាត់ស្លូតដែររឺមួយក៏កាច?

ខៈ  ម្ដាយរបស់ខ្ញុំគាត់ស្លូតដែរតើ!

កៈ
ចុះមីងមានចងចាំថាកាលពីមីងនៅជាមួយម្ដាយឪពុករបស់មីងនឹងធ្លាប់មានប្រវត្តិលក្ខណៈ
ថាដូចជា មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេ?

ខៈ  អនុស្សាវរីយ៍អីគេដែរ?

កៈ  ធ្លាប់ទៅណាជាមួយពួកគាត់ធ្លាប់លក់ដូរអីគេជាមួយពួកគាត់ដែរចឹង?

ខៈ  កាលណុងខ្ញុំភ្លេចបាត់ទៅហើយនឹង

កៈ  អូ្ហ!មីងភ្លេចបាត់ហើយហោសមីង?

ខៈ  ចា៎!ខ្ញុំដឹងថាត្រឹមធ្វើជី នឹងរើសអាចម៍គោអីចឹង ខ្ញុំចាំបានតែប៉ុណ្ណឹងណាស់ក្មួយ

កៈ  បាទ អត់អីទេបើមីងភ្លេចនឹង?

ខ៖ ខ្ញុំមិនសួរជាចងចាំអីទេ

ក៖
ចុះឪពុកម្ដាយរបស់មីងនឹងគាត់មានធ្លាប់ប្រាប់ប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅមីងដែរទេ?

ខ៖ គាត់ប្រាប់ដែរតើ!

ក៖ គាត់ថាម៉េចខ្លះដែរទៅមីង?

ខ៖ គាត់ប្រាប់ថា ប៉ារបស់ខ្ញុំគាត់ប្រាប់ថាគាត់កើតនៅស្រុកចិន
ចឹងនៅស្រុកចិនគេធ្វើសង្គ្រាមគេចាប់ធ្វើ ជាទាហ៊ានហាស

ក៖ បាទមីងចុះគាត់នៅចិននឹងគាត់នៅខេត្តណាមីងមានដឹងអត់?

ខ៖ អូ្!ខ្ញុំអត់បានដឹងរលីងនឹង

ក៖ បាទអត់អីទេមីង?

ខ៖ ខ្ញុំគ្រាន់តែដឹងថាគាត់នៅចិន គ្រាន់តែគាត់និយាយថានៅចិននឹងគេចាប់ធ្វើជាទាហ៊ាន គេល្បីថានៅស្រុកខ្មែរនឹងវាឯករាជ្យណាស់

ក៖ អូ្!បាទមីង?

ខ៖ ចឹងទៅគាត់នាំក្រុមគាត់ប្រហែលជា10ក្រុមហោសមកនៅស្រុកខ្មែរនឹងទៅ

ក៖ អូ្!ដល់ពេលចឹងបានមកយកប្រពន្ធនៅស្រុកខ្មែរចឹងទៅ?

ខ៖ នឹងហើយដូចថាខ្មែរយើងរកស៊ីបានដូចសព្វថ្ងៃអីចឹងទៅណាស់

ក៖ អូ្!បាទចឹងគេលែងទៅវិញទៅ?

ខ៖
នឹងហើយគេដាក់ចិត្តលែងទៅវិញចឹងទៅគាត់មកនៅស្រុកខ្មែររហូតទាល់តែគាត់ស្លាប់ចឹងទៅ

ក៖ បាទមីង ចុះយាយតាខាងឪពុកនឹងមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ អត់ស្គាល់រលីង

ក៖ អ៎ូ!អត់ស្គាល់ទេណាមីង?

ខ៖ អត់បានស្គាល់ទេនឹង

ក៖ ចុះយាយតាខាងម្ដាយវិញមីងស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ យាយតាខាងម្ដាយខ្ញុំស្គាល់តើ!

ក៖ ពីព្រោះតែគាត់នៅខ្មែរនឹងណាមីង?

ខ៖ ចា៎!គាត់នៅខ្មែរនឹង

ក៖ ចុះគាត់មានឈ្មោះអីគេដែរមីង?

ខ៖ ម៉ាររបស់ខ្ញុំនឹងឈ្មោះសៀង ហើយកុងរបស់ខ្ញុំនឹងឈ្មោះលុក

ក៖ ចុះកុងម៉ាខាងម្ដាយរបស់មីងនឹងមានដឹងថាគាត់កើតនៅណាដែរទេ?

ខ៖ គាត់កើតនៅគងពិសីនឹងដែរនឹង

ក៖ គាត់កើតនៅគងពិសីនឹងហោសមីង?

ខ៖ ចា៎!នៅនឹង

ក៖ ចុះមីងមកនៅខេត្តនឹងយូរនៅមីង?

ខ៖ ខ្ញុំមកនៅតាំងពីឆ្នាំ1999មកនឹង

ក៖ ចឹងមានន័យថាមីងមកនៅអស់19ឆ្នាំហើយណាមីង?

ខ៖ ចា៎!ប៉ុណ្ណឹង

ក៖ ចឹងមីងមានបងប្អូនរឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេមីង?

ខ៖ អត់មានទេអូន

ក៖ អត់មានទេបងប្អូនកូនក្មួយក៏អត់មានដែរណាមីង?

ខ៖ អត់មានទេ

កៈ នៅថៃ វៀតណាមក៏អត់មានដែរហោសមីង?

ខៈ អត់មានទេ

កៈ ចុះស្វាមីរបស់មីងនឹងឈ្មោះអីគេដែរមីង?

ខៈ ស្វាមីរបស់ខ្ញុំឈ្មោះលេង ប៊ុន ថេត

កៈ ចុះមីងមានចងចាំថ្ងៃដែរមីងរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ដែរទេមីង?

ខៈ ខ្ញុំចាំបានតើ!

កៈ ដូចជានៅថ្ងៃខែឆ្នាំណា?

ខៈ កាលពីការជាមួយគាត់នឹងនៅឆ្នាំ1987

កៈ នៅឆ្នាំ1987ហោសមីង ចុះខែវិញខែអីគេទៅមីង?

ខៈ ខ្ញុំការជាមួយគាត់នឹងនៅខែជេស ខែជេសនឹងខែអីគេដែរទៅ

កៈ ខែជេសនឹងខ្ញុំមិនសូវដឹងដែរនឹងខ្ញុំមិនសូវដឹងខែខ្មែរដែរនឹង

ខៈ ខែចៃត្រតែ4 ខែជេសខែ6ហោស?

កៈ ខ្ញុំអត់ចេះដែរនឹងខែខ្មែរនឹង

ខៈ មើលខែចៃត្រ ពិសាខ ខែជេស ត្រូវខែ6នឹង

កៈ ខែជេសនឹងនៅខែមិថុនាណមីង?

ខៈ ចា៎!នឹងហើយ

កៈ ចុះនៅពេលដែរមីងរៀបអាពាហ៍ពិពាហ៍នឹង តើមីងជាអ្នករៀបខ្លួនឯង រឺឪពុកម្តាយជាអ្នករៀបអោយ ដែរមីង?

ខៈ ម្តាយឪពុកជាអ្នករៀបអោយនឹង

កៈ ប៉ុន្តែនៅពេលដែរពូចូលស្តីដណ្តឹងមីងនឹងដូចជាមានជាបណ្ណាការទេមីង?

ខៈ មានតើ

ក៖ ដូចជាពេលណុងគេអោយអីគេដែរមីងអាចប្រាប់បានទេ?

ខ៖ កាលណុងផ្ទះនៅធូរថ្លៃហើយតែពីរម៉ឺននឹង

ក៖ អ៊ូ!គាត់ផ្គាប់ជាផ្ទះតែម្តងហោសមីង?

ខ៖ ចុះកាលណុងដូចថាយើងទើបតែចេញពីអាពតនឹងយើងមានស្អី

ក៖ បាទមីង ចុះមីងអាចប្រាប់ពីប្រវត្តិស្នេហាតិចបានទេ
ថាតើពូជួបមីងនៅពេលណាហើយហេតុអីបាន ជាគាត់ស្រលាញ់មីង
ហើយគាត់ស្រលាញ់បានប៉ុន្មានឆ្នាំបានគាត់ចូលស្តីដណ្តឹងមីងចឹងទៅ?

ខ៖ ខ្ញុំអត់មានប្រវត្តិទេ
ដូចថាចេះម៉ែហើយនឹងពូគាត់មើលឃើញគ្នាចឹងទៅពួកគាត់ជាអ្នកផ្សំផ្គុំអោយចឹង
ទៅណាស់ដូចថាមានប្រវត្តិយូរអីអត់មានទេ

ក៖ ចុះមីងធ្លាប់បានរៀនភាសាខ្មែរដែរទេមីង?

ខ៖ ខ្ញុំមិនបានរៀនទេនឹង

ក៖ ចឹងអត់បានរៀនសោះតែម្តងមីង?

ខ៖ ចុះអោយរៀនយ៉ាងម៉េចបើនៅអាពតរៀនអករះកម្មនឹង

ក៖ រៀនលក្ខណះអករះកម្មហោសមីង?

ខ៖ រៀនអករះកម្មនឹងណា

ក៖ ចុះមីងមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេ ដូចជាភាសាចិន

ខ៖ អត់មានចេះទេនឹង

ក៖ ភាសាវៀតណាម ថៃអីក៏អត់ដែរហោសមីង?

ខ៖ អត់ទេនឹង តែខ្មែរនឹងខ្ញុំរៀនអត់ចេះផងនឹងខ្ញុំសរសេរជើងឡើងលើនឹង

ក៖ អ៊ូ!មីងសរសេរឡើងលើហោសមីង?

ខ៖ នឹងហើយបើរៀនមិនចេះផង

កៈ ចុះមីងមានមិត្តភក្តិណាដែរធំធាតមកជាមួយគ្នាដែរទេកាលពីតូចហាស?

ខៈ កាលពីតូចមាន ប៉ុន្តែឥឡូវនឹងគេបែកអស់ហើយនឹងដូចថាគេទៅនៅខេត្តកំពង់ឆ្នាំង រឺក៏គេបានទៅ នៅខេត្តពោសាត់អីចឹងទៅយូរៗគេណាយគ្នាអស់ចឹងទៅណាស់

កៈ បាទមីង ប៉ុន្តែមីងមានចងចាំឈ្មោះពួកគាត់ដែរទេមីង?

ខៈ មានចងចាំតើ!

កៈ ចុះពួកគាត់មានឈ្មោះអីគេខ្លះដែរទៅមីង?

ខៈ ខាន់ជួបគ្នាយូរហើយនឹង

កៈ ប៉ុន្តែមីងអាចរើបរាប់ឈ្មោះពួកគាត់ដែរបានទេមីង?

ខៈ រៀបរាប់ឈ្មោះពួកគាត់នឹងហោស?

កៈ បាទពួកគាត់អ្នកនៅកំពង់ឆ្នាំ?

ខៈ អ្នកនៅលាប់លែង

កៈ ដូចនៅលាប់លែងអីនឹង?

ខៈ មានមិត្តភក្តិដូចថាជាបង ខន បងរី គេបងយើងមួយឆ្នាំអីចឹងទៅណាស់

កៈ បាទមីងបាទមានអីទៀតទេ?

ខៈ រឺក៏គេប្អូនយើងមួយឆ្នាំអីចឹងទៅណាស់

កៈ បាទមីង?

ខៈ ខ្លះទៅអាយុស្តូរៗគ្នានឹង

កៈ
ចុះមីងមានចងចាំថាមីងធ្លាប់ធ្វើអីគេខ្លះជាមួយមិត្តភក្តិរបស់មីងកាលពីនៅក្មេងៗថាធ្លាប់បានលេងអី គេជាមួយគ្នាចឹងណាស់មីង?

ខៈ មានប៉ុន្តែគ្រាន់ថាអនុស្សាវរីយ៍កាលខ្ញុំនៅពីក្មេងក្រៅពីម៉ោងលោតទឹក លោតអីចឹងទៅលោតក្រម៉ា លោតកៅស៊ូចឹងទៅកាលនៅក្មេងៗណាស់

កៈ ទៅចាប់ត្រី ទៅចាប់ក្តាមអីជាមួយគ្នាចឹងទៅណាមីង?

ខៈ នឹងហើយចឹង

កៈ ប៉ុន្តែភាគច្រើននៅណាដែរមីង នៅស្រុកនឹងរឺមួយនៅណាផ្សេងដែរមីង?

ខៈ ខ្ញុំនៅច្រើនណាស់អូនបើនិយាយពីប្រវត្តិរបស់ខ្ញុំមានច្រើនណាស់ នេះស្រុកខាងប្តីទេ

កៈ អូ!ចឹងស្រុកខាងមីងនៅណាដែរមីង?

ខៈ ស្រុកខាងខ្ញុំនៅគងពិសី

កៈ អូ!នៅស្រុកគងពិសីហោសមីង?

ខៈ
ដូចថាខ្ញុំការហើយបានមួយឆ្នាំចឹងទៅខ្ញុំនាំគ្នាទៅរកស៊ីនៅណោះនៅជិតកំពង់សោមហោស

កៈ បាទបានឆ្ងាយដែរមីង?

ខៈ ចឹងខ្ញុំទៅរកនៅណុងបានមួយឆ្នាំទៅពីរឆ្នាំចឹងទៅ
ខ្ញុំត្រលប់ពីនឹងមគខ្ញុំមកនៅដីក្រហម

កៈ អូ!ដីក្រហមនៅណាដែរមីង?

ខៈ ចា៎!ដីក្រហមនៅផ្លូវយើងទៅកំពង់សោមនឹង

កៈ ប៉ុន្តែនៅកំពង់ស្ពឺនឹងទេ?

ខៈ អត់ទេ

កៈ ចឹងទឹកដីនៅកំពង់សោមនឹង?

ខៈ ចា៎!នៅកំពង់សោមនឹង ចេញពីកំពង់សោមនឹងខ្ញុំមកនៅស្រែអំបិល
ហើយចេញពីស្រែអំបិលមកបាន ខ្ញុំមកនៅនេះ

កៈ ប៉ុន្តែមីងអត់ទៅរកស៊ីនៅស្រុកកំណើតរបស់មីងនៅគងពិសីទេ?

ខៈ អត់បាននៅទេពីព្រោះខ្ញុំធំការចឹងទៅតាមប្តីចេះរកចឹងទៅណាស់

កៈ បាទពេលដែរមីងទៅណាមីងក៏ទៅរកជាមួយគ្នាទៅណាស់មីង?

ខ៖ ចា៎!នឹងហើយ

ក៖
មីងគិតថាតាំងពីតូចរហូតមកដល់ពេលនេះមីងគិតថាមីងធ្លាប់ធ្វើការងារអីគេខ្លះដែរមីង?

ខ៖ តាំងពីតូចមកដល់ប៉ុណ្ណឹងមកមានស្អី មានតែជំនាន់អាពតនឹងធ្វើចឹង
ប៉ុន្តែតាំងពីចេញពីប្តីមកដូចថា យើងលក់ត្រីលក់បន្លែអីចឹងទៅ

ក៖ បាទចឹងមីង?

ខ៖ រឺមួយយើងអាចលក់ឥវ៉ាន់ចាប់ហ៊ួយចិញ្ចឹមខ្លួនចឹងទៅណាស់

ក៖ អូ៎!បាទមីងចឹង?

ខ៖ ប៉ុន្តែបើអោយបើហាងធំដុំដូចគេនឹងគ្មានទេនឹង

ក៖ បាទមីង ចុះមីងគិតថាមីងធ្លាប់ទៅធ្វើការនៅវាលស្រែមែនទេមីង?

ខ៖ មានតើ!

ក៖ មីងធ្វើអីគេនៅស្រែដែរមីង?

ខ៖ ទៅស្រែរើសអាចម៍គោ កាប់កន្ទ្រាំងខែតយកមកធ្វើជាជី រែកទឹករែកដីអីចឹងទៅ

ក៖ មានដកស្ទូងអីនឹងមានទេមីង?

ខ៖ មានតើ!

ក៖ អូ៎!ច្រូតកាត់អីណាមីង?

ខ៖ មានដែរនឹងតើ!

ក៖ ចុះមីងគិតថាមីងធ្លាប់លក់ដូរជាអាជីវកម្មអីផ្សេងៗទេមីង?

ខ៖ មានតើ ដូចថាខ្ញុំលក់បន្លែចឹងទៅទួលកញ្ច្រែងដើរលក់ចឹងទៅ
ចុះជីវិតយើងអត់ណាស់អូន

ក៖ បាទត្រូវហើយមីង?

ខ៖ លក់ត្រកួនអីចឹងដើរបេះតាមអូរ តាមបឹងស្រែ តាមត្រពាំងបឹងទឹកអីចឹងទៅ អីក៏ដែរៗអូន

ក៖ ចុះមីងគិតថាមីងធ្លាប់ចិញ្ចឹមសត្វទេមីង ដូចថាចិញ្ចឹមមាន់ ទា ជ្រូក គោ ក្របីអីចឹងហាសមីង?

ខ៖ មានចិញ្ចឹមតើអូន

ក៖ មីងមានចិញ្ចឹមអីគេដែរមីង?

ខ៖ មីងចិញ្ចឹមគោ

ក៖ ចិញ្ចឹមគោហោសមីង ចិញ្ចឹមលក្ខណះជាកសិដ្ឋាន រឺមួយចិញ្ចឹមជាលក្ខណះគ្រួសារមីង?

ខ៖ ចិញ្ចឹមលក្ខណះជាគ្រួសារនឹងណាស់ ដូចជាមានមេមួយពីរនឹងហាស

ក៖

ចុះមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេខ្លះដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ មានការផ្លាស់ប្តូរច្រើនណាស់អូន

ក៖ មានការផ្លាស់ប្តូរអីគេដែរមីង?

ខ៖ មានការផ្លាស់ប្តូរច្រើនណាស់ តាំងពីកំសត់ តាំងពីអត់កំសត់នឹង

ក៖ អូ៎!បាទមីង?

ខ៖ មានច្រើនណាស់អូនអើយ

ក៖ ចុះមីងគិតថាម្ហូបអីដែរមីងចូលចិត្តពិសារហោសមីង?

ខ៖ រាល់ថ្ងៃនឹងមែន?

ក៖ បាទមីង?

ខ៖ ខ្ញុំចូលចិត្តតែប្រហុកអីនឹង

ក៖ ប្រហុកមែនមីង?

ខ៖ នឹងហើយប្រហុកនឹង

ក៖ ប៉ុន្តែលក្ខណៈថាចៀន ឆា ការី កក្កូរអីនឹងមីងចូលចិត្តទេ?

ខ៖ ចង់និយាយថាមានដោយពេលចឹងណាស់មានថ្ងៃខ្លះឆ្ងាញ់
មានថ្ងៃខ្លះអត់ឆ្ងាញ់ចឹងទៅណាស់

ក៖ ប៉ុន្តែគ្រាន់តែថាបើមីងចូលចិត្តតែម្តងនឹងគឺប្រហុក?

ខ៖ ចាំ!នឹងហើយ

ក៖ ដែរមីងគិតថាលក្ខណៈថាចូលចិត្តហើយឃ្លាននឹង?

ខ៖ នឹងហើយប្រហុកនឹង

ក៖ ចុះល្បែងប្រជាប្រិយ៍អីដែរមីងគិតថាមីងចូលចិត្តលេងតាំងពីក្មេងណាស់មីង
ដូចជាចោលឈូង ទាញព្រាត លាក់កន្សែ ?

ខ៖ ខ្ញុំថាអត់មាន ចុះចឹមិនដឹងចុះយើងមិនចូលខ្មែរក្រហមអាពតហោស

ក៖ បាទចឹងហោសមីង?

ខ៖ ដល់ពេលដែរយើងចេញមកវាធំហើយនឹង
ដល់ពេលដែរធំចឹងទៅយើងមានបានទៅលេងអីណាបើ យើងខំជួយរកស៊ីម៉ែនឹង

ក៖ អូ!ចឹងណោះមីង?

ខ៖ នឹងហើយដូចជាលក់ក្រសាំង លក់ត្រកួន ដើម្បីទិញអង្ករហូបចឹងទៅណាស់

ក៖ បាទមីងបាទ?

ខ៖ នឹងវាចឹងឯង

ក៖ ចុះមីងចេះច្រៀងដែរទេមីង?

ខ៖ អត់មានចេះទេ

ក៖ ចុះមីងចូលចិត្តស្តាប់បទចំរៀងទេ?

ខ៖ ខ្ញុំចូលចិត្តដែរតើ!

កៈ លក្ខណៈជាបទបុរាណ រឺមួយបទសម័យ
រឺបទបរទេសដែរមីងចូលចិត្តស្តាប់ចឹងណាស់មីង?

ខៈ ខ្ញុំចូលចិត្តតែបុរាណទេ

កៈ ចឹងមីងចូលចិត្តតែបុរាណទេណាមីង?

ខៈ ចា៎!នឹងហើយបទបុរាណពិរោះ

កៈ ចុះមាននរណាគេនៅក្នុងក្រុមគ្រួសាររបស់មីងចេះលេងឧបករណ៍ភ្លេងដៃរទេមីង?

ខៈ អត់មាន

កៈ លក្ខណៈភ្លេងពិនពាត ភ្លេងខ្មែរ ភ្លេងសៀមអីក៏អត់ចេះដែរណាមីង?

ខៈ អត់មានចេះទេនឹង

កៈ
ចុះផ្ទះរបស់មីងមានលក្ខណៈបែបណាដែរមីងតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង
ដូចថាកាលពីក្មេងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចដែរចឹងមីង?

ខៈ
រឿងផ្ទះសំបែងនឹងមួយជីវិតរបស់មីងនឹងមិនទាន់ដឹងថាមានផ្ទះសំបែកល្អនៅយ៉ាងម៉េចទេ
នឹង ដូចថាចុះយើងផ្ទះធំមកនៅអាពត

កៈ បាទមីងបាទ?

ខៈ ដូចថាផ្ទះធំ
រឺមួយក៏គ្រឿងជំរុះគ្រឿងល្អៗអីចឹងគេបានដកហូតចេញពីខ្លួនយើងអស់ហើយនឹង

កៈ ចឹងហោសមីង?

ខៈ យើងមានតែសារ៉ុងមួយ នឹងអាវមួយនៅជាប់នឹងខ្លួននឹង

កៈ ប៉ុន្តែផ្ទះឥឡូវនឹងយ៉ាងម៉េចដែរមីង?

ខៈ ផ្ទះមីងនឹងមើលទៅ

កៈ ណាផ្ទះរបស់មីងហោសមីង?

ខៈ នឹងផ្ទះនឹងឯង

កៈ អូ៎!ផ្ទះនឹងហោសមីង ផ្ទះធំល្អផង ខ្ញុំគ្មានផ្ទះនៅផងខ្ញុំជួលគេនឹងនៅភ្នំពេញនឹង

ខៈ ជួលគេនឹងផ្ទះមានការ៉ូអីនឹង

កៈ បាទមីងចុះមីងគិតថានរណាគេជាអ្នកសាងសងផ្ទះមួយនឹងដែរមីង?

ខៈ ខ្ញុំពីរនាក់ប្តីប្រពន្ធនឹង

កៈ ប៉ុន្តែមីងជួលគេធ្វើ រឺមួយក៏ប្តីរបស់មីងគាត់ចេះធ្វើផ្ទះដែរមីង?

ខៈ ខ្ញុំជួលគេនឹង

កៈ អូ៎!ជួលគេលក្ខណះថាអោយលុយគេទៅអោយគេធ្វើអោយណាមីង?

ខៈ ចា៎!នឹងហើយធ្វើចឹង

កៈ ប៉ុន្តែមីងមានដឹងថាគេធ្វើផ្ទះរបស់មីងនឹងគេមានប្រើឧបករណ៍អីគេសំរាប់ធ្វើដែរទេមីង?

ខៈ គេធ្វើនឹងមានស្អីក្ខយមានតែចបកាប់ទុកកាប មីងធ្វើដើមត្នោតតើ គ្មានឈើទេ

កៈ អូ៎!បាទមីងបាទ?

ខៈ

លក្ខណះដើមត្នោតចាស់ៗពីសង្គមមកនឹងឪពុកខាងប្តីរបស់ខ្ញុំនឹងគេអោយម្នាក់មួយដើមមកនឹង

កៈ អូ៎!ចឹងហោសមីងឡូយដែរនឹងមីង?

ខៈ ខ្ញុំយកដើមត្នោតធ្វើតើនឹង

កៈ ចុះមីងគិតថាជំនាញអីដែរមីងគិតថាមីងចេះស្ទាត់ជំនាញដែរមីង?

ខៈ អត់មានចេះអីផងនឹង

កៈ លក្ខណះថាលក់ដូរ?

ខ៖  ចា៎!ចេះតែលក់ដូរនឹងចេះតែប៉ុណ្ណឹង

ក៖  ចុះមីងគិតថាឪពុកម្ដាយរបស់មីងធ្លាប់បង្រៀនពីជំនាញអីទៅមីងទេដូចជាវេញវល្លិ៍ធ្វើផ្ដៅ កូរស្ករត្នោត ធ្វើជាក្រម៉ាអីទេមីង?

ខ៖  អត់មានទេ

ក៖  អត់មានទេហោសមីង?

ខ៖  ចា៎!អត់មានតែម្ដងនឹង

ក៖  ចុះមីងគិតថាតាំងពីក្មេងនឹងមានការលំបាកអីគេខ្លះដែរមីង?

ខ៖  លំបាកដូចថាយើងទីទាល់ក្រយើងអត់ណាស់ ដូចថាយើងមានតែកំលាំង

ក៖ អ៎ូ!បាទមីង?

ខ៖  មានគេបេះផ្លែក្រសាំង មានគេបេះស្លឹកអំពិលដើរទូលលក់អីចឹងណាស់មីង

ក៖  បាទត្រូវហើយមីង?

ខ៖  គ្រាន់តែថាវាមិនបានលក់ច្រើនដូចគេអីចឹងទៅណាស់

ក៖  ចុះមីងគិតថាមីងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរមីង?

ខ៖  កាលពិបាកនឹងពិបាកខ្លាំងដែរនឹងអូន
បើយើងមិនទៅរកនឹងយើងមិនបានអីទិញអង្ករដើម្បីហូបប្រចាំ ថ្ងៃនឹងអូន

ក៖  បាទមីង ចុះបើចង់និយាយពីពេលសប្បាយវិញ
គិតថាពេលណាដែរមីងគិតថាជាពេលដែរសប្បាយ
ជាងគេនៅក្នុងឆាកជីវិតរបស់មីងវិញដែរ?

ខ៖  មីងដូចថាអត់សង្ឃឹមតែម្ដងនឹង
ដូចថាឥឡូវនឹងអាយុ50ឆ្នាំជាងហើយមីងអស់សង្ឃឹមហើយនឹង

ក៖
ចុះតាំងពីក្មេងនឹងមីងធ្លាប់មានក្ដីស្រម៉ៃថាពេលដែរមីងធំឡើងនឹងមីងចង់ធ្វើអីគេដែរទេមីង
?

ខ៖
តាំងពីនឹងមកមាននឹកឃើញដែរនឹងប៉ុន្តែដូចថាជំនាន់នឹងវានៅអាពតចឹងវាត្រូវរៀនអករះក
ម្មចឹងណា មួយថ្ងៃគេអោយរៀនតែមួយម៉ោងទេនឹង

ក៖ អូ៎!ចឹងហោសមីង?

ខ៖
ហើយចេញពីមួយម៉ោងនឹងមកអោយយើងទៅធ្វើការដូចអ្វីដែរខ្ញុំនិយាយចឹងមានតែប៉ុណ្ណឹង

ក៖ អូ៎!ចឹងទេពេលណុង?

ខ៖ នឹងហើយគ្មានបានដើរបង្រៀនអោយយើងចេះនេះ
ចេះនោះទេនឹងគេអោយយើងធ្វើតែចឹងអោយវែក តែដីនឹង
ធ្វើប្រឡាយកាប់ធ្វើជាជីមិនថាតូច
មិនថាធំទេអោយតែធំតិចនឹងគេហៅថាកុមារឈានមុខហើយនឹង

ក៖ បាទមីងមានអីទៀតទេ?

ខ៖ ចាំ!ដូចបងរបស់ខ្ញុំចឹងគាត់ធំគេហៅយុវនារីឈានមុខ គេហៅនារីកងស្រួច

ក៖ ចុះបើចង់អោយមីងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗរបស់មីង
តើមីងចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរ?

ខ៖ ចង់និយាយថាមិនចង់អោយមានកើជំនាន់អាពតទៀតចឹងណាស់

ក៖ អូ៎!បាទចឹងហោសមីង?

ខ៖ ចង់អោយកើតដូចថានៅជំនាន់តជោនឹងណាស់
នឹងអោយសង្គមតឡូវនឹងអោយសប្បាយរហូតនឹង

ក៖ បាទល្អតើមីង?

ខ៖ ចាំ!មានតែចឹង

ក៖ ចុះបើសិនជាចង់អោយពួកគាត់ជៀសវាងវិញ
តើមីងចង់អោយពួកគាត់ជៀសវាងអីគេដែរមីង?

ខ៖ ខ្ញុំចង់អោយជៀសវាងជាងគេជាពិសេសនឹង
លេខមួយបំផុតនឹងគឺបំបាត់គ្រឿងញៀននឹងតែម្តងនឹង

ក៖ អ៎ូ!បាទត្រូវមីង?

ខ៖ ចា៎!ខ្ញុំចង់អោយបាត់តែម្តងនឹងមិនចង់អោយមានកើតឡើងទេនឹង

ក៖ មានអីទៀតដែរមីងចង់ផ្តែផ្តាំទៅពួកគាត់ដែរទេនឹង
លក្ខណះថាពេលដែរពួកគាត់បើកបរមិនអោយ
ពួកគាត់ពិសារគ្រឿងស្រវឹងអីចឹងហាសមីង?

ខ៖ ចា៎!ចង់អោយចឹងនឹងហើយ

ក៖ ចុះមានអីផ្សេងអីទៀតទេមីង?

ខ៖ ចា៎!ខ្ញុំសុំណូមពរចង់បានតែពីរនឹងទេ

ក៖
ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានផ្តល់ពេលវេលាដែរបានពិភាក្សាជាមួយខ្ញុំដែរទាក់ទង ទៅនឹងប្រវត្តិរបស់មីង
ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលា
ដើម្បីតំកល់ទុកអោយមីង

ខ៖ ចា៎!នឹងហើយ

ក៖ ចឹងជាចុងក្រោយខ្ញុំនឹងយកប្រវត្តិរបស់មីងអោយមីងមួយទៀតចឹងណាស់មីង

ខ៖ ចា៎!អរគុណក្មួយ

ក៖ បាទចឹងខ្ញុំអរគុណច្រើនមីង៕៕៕